# ព្រះរាជក្រឹត្យ

នស/រកត/០៤០០/០៧៥

## ស្តីពី

## លក្ខន្តិកៈដោយឡែក

## នៃក្របខ័ណ្ឌមន្ត្រីក្រមការ

## ក្រសួងមហាផ្ទៃ

## យើង

## ព្រះបាទសម្តេចព្រះនរោត្តមសីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០០

## ប្រកាសបង្គាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតក្របខ័ណ្ឌមន្ត្រីក្រមការរបស់ក្រសួងមហាផ្ទៃ ដែលត្រូវបានចាត់ថ្នាក់ក្នុងប្រភេទ **ខ** ដូចមានចែងក្នុងមាត្រា ៣ នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ១៩៩៧ ស្ដីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ។

**មាត្រា ២.-**

មន្ត្រីរាជការនៃក្របខ័ណ្ឌមន្ត្រីក្រមការនេះ ត្រូវស្ថិតនៅក្រោមឱវាទក្រសួងមហាផ្ទៃ។

**មាត្រា ៣.-**

មន្ត្រីរាជការនៃក្របខ័ណ្ឌមន្ត្រីក្រមការ មានភារកិច្ចជាជំនួយការដល់មន្ត្រីរដ្ឋបាលជាន់ខ្ពស់ ហើយមានឧបនិស្ស័យក្នុងការបំពេញមុខងារក្នុងតំណែងដឹកនាំអង្គភាពថ្នាក់មធ្យម នៅរដ្ឋបាលកណ្ដាលរបស់ក្រសួងមហាផ្ទៃ និងតាមខេត្ត ក្រុង។

## ជំពូកទី ២

## ឋានន្តរស័ក្តិ ថ្នាក់ និង មុខតំណែងក្របខ័ណ្ឌ

**មាត្រា ៤.-**

ក្របខ័ណ្ឌមន្ត្រីក្រមការមាន ៣ ឋានន្តរសក្តិ ៖

- នាយក្រមការ : មាន ០៦ ថ្នាក់
- ក្រមការដើមខ្សែ : មាន ១០ ថ្នាក់
- ក្រមការ : មាន ១៤ ថ្នាក់។

**មាត្រា ៥.-**

មន្ត្រីក្នុងឋានន្តរសក្តិ នាយក្រមការ មានឧបនិស្ស័យសំរាប់កាន់មុខតំណែងជា ៖

- ប្រធានការិយាល័យ ក្នុងរដ្ឋបាលកណ្ដាល
- អនុប្រធានមន្ទីរនៅខេត្តក្រុង
- អភិបាលរងស្រុក ខ័ណ្ឌ

និងមុខតំណែងឯទៀតដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួងមហាផ្ទៃ។

មន្ត្រីក្នុងឋានន្តរសក្តិ ក្រមការដើមខ្សែ មានឧបនិស្ស័យ សំរាប់កាន់មុខតំណែងជា ៖

- អនុប្រធានការិយាល័យ ក្នុងរដ្ឋបាលកណ្ដាល
- ប្រធានការិយាល័យនៅសាលាខេត្ត ក្រុង

និងមុខតំណែងឯទៀតដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួងមហាផ្ទៃ។

មន្ត្រីរាជការក្នុងឋានន្តរសក្តិ ក្រមការ មានឧបនិស្ស័យ សំរាប់កាន់មុខតំណែងជា ៖

- អនុប្រធានការិយាល័យ នៅសាលាខេត្ត-ក្រុង

និងមុខតំណែងឯទៀតដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួងមហាផ្ទៃ។

## ជំពូកទី ៣
## ការជ្រើសរើស និង ការបណ្តុះបណ្តាលដំបូង

**មាត្រា ៦.-**

ការជ្រើសរើសចូលក្នុងក្របខ័ណ្ឌមន្ត្រីក្រមការ ត្រូវធ្វើតាមរយៈការប្រឡងប្រជែង ក្នុងចំណោមមន្ត្រីរាជការ ឬ និង ក្នុងចំណោមនិស្សិត។ ចំនួននៃតំណែងដែលត្រូវផ្តល់ក្នុងការប្រឡងប្រជែងសំរាប់មន្ត្រីរាជការ និងនិស្សិត ត្រូវកំណត់ដោយរាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួងមហាផ្ទៃ។

**មាត្រា ៧.-**

ការប្រឡងប្រជែងក្នុងចំណោមនិស្សិត ត្រូវធ្វើចំពោះបេក្ខជនដែលមានសញ្ញាប័ត្រយ៉ាងទាបមធ្យមនីតិសាស្ត្រ ឬសញ្ញាប័ត្រដែលមានតំលៃស្មើ និងមានអាយុយ៉ាងច្រើន ២៥ ឆ្នាំ គិតរហូតដល់ថ្ងៃប្រឡង។ អាយុនេះអាចរំកិលពី ២៥ ឆ្នាំ ឡើងដល់ ៣០ ឆ្នាំ ស្របតាមមាត្រា ១១ នៃ សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។

បេក្ខជនដែលត្រូវបានជ្រើសរើសតាមរយៈការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ ត្រូវធ្វើចំពោះមន្ត្រីរាជការដែលស្ថិតយ៉ាងទាបបំផុត ក្នុងថ្នាក់លេខ ១១ របស់ក្របខ័ណ្ឌប្រភេទ **គ** និងមានអាយុយ៉ាងច្រើន ៤០ ឆ្នាំ។

ចំពោះមន្ត្រីរាជការរបស់ក្រសួងមហាផ្ទៃ ដែលមានសញ្ញាប័ត្រសមមូលនឹងមធ្យមសិក្សាបត្រ័ភាគទី ២ បូកនឹងពីរឆ្នាំសិក្សាក្នុងគ្រឹះស្ថានឧត្តមសិក្សាដែលមានសញ្ញាប័ត្រ អាចប្រឡងចូលក្នុងក្របខ័ណ្ឌនេះបាន ដោយពុំគិតពីល័ក្ខខ័ណ្ឌឋានន្តរសក្តិ និងប្រភេទក្របខ័ណ្ឌឡើយ ហើយមានអាយុយ៉ាងច្រើនបំផុត ៤០ ឆ្នាំ។

**មាត្រា ៨.-**

បេក្ខជនដែលត្រូវបានជ្រើសរើស តាមរយៈការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ និងឬក្នុងចំណោមនិស្សិត មានឋានៈជាសិស្សមន្ត្រីក្រមការ ហើយត្រូវទទួលការបណ្តុះបណ្តាលដំបូងនៅសាលាភូមិន្ទរដ្ឋបាល។

## ជំពូកទី ៤
## កម្មសិក្សា និង ការតាំងស៊ប់

**មាត្រា ៩.-**

បន្ទាប់ពីការបណ្តុះបណ្តាលដំបូង សិស្សក្រមការ ត្រូវបានចាត់ឱ្យទៅបំរើការងារតាមអង្គភាពនានាក្រោមឱវាទក្រសួងមហាផ្ទៃ ហើយត្រូវបានតែងតាំងជាមន្ត្រីក្រមការកម្មសិក្សា ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ។

មន្ត្រីកម្មសិក្សាទាំងនេះ ត្រូវឆ្លងកាត់កម្មសិក្សា មួយដែលមានរយៈពេលដូចខាងក្រោម ៖

១- ១២ ខែ ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីនិស្សិត។

២- ០៦ ខែ ចំពោះមន្ត្រីត្រូវបានជ្រើសរើសចេញមកពីមន្ត្រីរាជការ ហើយដែលពីមុននេះពុំស្ថិតក្នុងក្របខ័ណ្ឌលេខាធិការរដ្ឋបាល ឬ ក្របខ័ណ្ឌអនុរក្សពន្ធនាគារ។

ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញមកពីមន្ត្រីរាជការ ហើយដែលពីមុននេះស្ថិតក្នុងក្របខ័ណ្ឌលេខាធិការរដ្ឋបាល ឬក្របខ័ណ្ឌអនុរក្សពន្ធនាគាររបស់ក្រសួងមហាផ្ទៃ ពុំចាំបាច់ឆ្លងកាត់កម្មសិក្សាសាកល្បងឡើយ។

ក្រោយពេលធ្វើកម្មសិក្សាសាកល្បង មន្ត្រីដែលចែងក្នុងចំណុចទី ១ និង ទី ២ ខាងលើត្រូវបានតាំងស៊ប់ក្នុងឋានន្តរសក្តិក្រមការ។ ក្នុងករណីពិសេស អាចត្រូវបានអនុញ្ញាតអោយធ្វើកម្មសិក្សាបន្តបន្ថែម ដែលមានរយៈពេលអតិបរមាត្រឹម ១២ ខែ ចំពោះមន្ត្រីដែលមានចែងក្នុង ចំណុច ទី១ និង ០៦ ខែ ចំពោះមន្ត្រីដែលមានចែងក្នុងចំណុចទី ២ ។ មន្ត្រីដែលពុំបានទទួលជោគជ័យក្នុងការបំពេញកម្មសិក្សាបន្ថែមនេះ ត្រូវលុបឈ្មោះចោលប្រសិនចេញមកពីនិស្សិត ឬ

មួយបញ្ចូលទៅក្របខ័ណ្ឌដើមវិញ ប្រសិនចេញមកពីមន្ត្រីរាជការ ដោយគិតបញ្ចូលសម្រាប់អតីតភាពការងារ ។ ករណីខាងលើទាំងនេះ ត្រូវសំរេចដោយប្រកាសរបស់ក្រសួងមហាផ្ទៃ តាមសំណើរបស់អង្គភាពសាមី ដោយបញ្ជាក់នូវមូលហេតុ ធ្វើឡើងក្នុងរយៈពេលយ៉ាងយូរ ៣ ខែ ក្រោយការបញ្ចប់កម្មសិក្សា ។

មន្ត្រីក្រមការ ដែលត្រូវបានជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ ត្រូវបញ្ចូលទៅក្នុងថ្នាក់ដែលមានសន្ទស្សន៍បៀវត្សខ្ពស់លើបន្ទាប់ពីសន្ទស្សន៍បៀវត្សចាស់របស់សាមីខ្លួន ។

មន្ត្រីក្រមការ ដែលត្រូវបានជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមនិស្សិត ត្រូវបញ្ចូលទៅក្នុងថ្នាក់លេខ ១៤ នៃឋានន្តរសក្តិក្រមការ ។

ការតាំងស៊ប់ក្នុងឋានន្តរស័ក្តិក្រមការ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ត្រូវធ្វើឡើងដោយអនុក្រឹត្យ ។

## ជំពូកទី ៥

## ការតែងតាំង

**មាត្រា ១០.-**

ក្រោយពេលត្រូវបានតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីក្រមការរួចហើយ មន្ត្រីក្រមការទាំងនេះ អាចត្រូវបានតែងតាំងក្នុងមុខតំណែងទំនេរណាមួយ ដូចមានចែងក្នុងមាត្រា ៥ ខាងលើ ស្របតាមឋានន្តរសក្តិរបស់ខ្លួន ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ តាមបែបបទដូចបានកំណត់ក្នុងមាត្រា ២៨ នៃព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។

## ជំពូកទី ៦

## ការតម្លើងថ្នាក់ និង ការតម្លើងឋានន្តរស័ក្តិ

**មាត្រា ១១.-**

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីក្រមការ ត្រូវបានតម្លើងថ្នាក់ទៅតាមលក្ខខណ្ឌដូចបានចែងក្នុងមាត្រា ២០ និងមាត្រាបន្តបន្ទាប់នៃសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

លក្ខណៈសម្បត្តិជាមូលដ្ឋាន ដែលត្រូវពិនិត្យតម្លើងថ្នាក់មានដូចខាងក្រោម ៖

- គោរពវិន័យការងារបានត្រឹមត្រូវ
- មានស្មារតីទទួលខុសត្រូវ
- សម្រេចបានល្អនូវភារកិច្ចដែលប្រគល់អោយ
- មានសីលធម៌ល្អ ។

ការឡើងថ្នាក់នៃអ្នករាជការក្នុងក្របខ័ណ្ឌនេះ ត្រូវគិតក្នុងសមាមាត្រ ៣ ភាគ ៤ តាមវេនជ្រើសរើស និង ១ ភាគ ៤ តាមវេនអតីតភាព ។

**មាត្រា ១២.-**

គោលការណ៍នៃការតម្លើងឋានន្តរសក្តិ ត្រូវតែតម្លើងទៅក្នុងថ្នាក់ដំបូងនៃឋានន្តរសក្តិខ្ពស់លើបន្ទាប់ ឬក្នុងករណីចាំបាច់ ត្រូវតែតម្លើងទៅក្នុងថ្នាក់ដែលស្របជាមួយសន្ទស្សន៍ខ្ពស់លើបន្ទាប់ ពីសន្ទស្សន៍ចាស់របស់មន្ត្រីសាមី ។

ការតម្លើងឋានន្តរសក្តិ ត្រូវអនុវត្តអោយបានស្របជាមួយចំនួនតំណែងដែលទំនេរនៅក្នុងឋានន្តរសក្តិនោះ ហើយត្រូវធ្វើតាមរយៈការចុះឈ្មោះក្នុងតារាងតម្លើងឋានន្តរសក្តិ ឬតាមរយៈការប្រឡងប្រជែង ឬមួយតាមរយៈការបណ្តុះបណ្តាលរយៈពេលវែងនៅក្នុង ឬ ក្រៅប្រទេស ។

ការតម្លើងថ្នាក់ និង ការដំឡើងឋានន្តរសក្តិ ត្រូវសម្រេចដោយប្រកាសរបស់ក្រសួងមហាផ្ទៃ។

**មាត្រា ១៣.-**

អាចតម្លើងទៅក្នុងឋានន្តរសក្តិក្រមការដើមខ្សែ គឺមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ ១១ នៃឋានន្តរសក្តិក្រមការ។

អាចតម្លើងទៅក្នុងឋានន្តរសក្តិនាយក្រមការ គឺមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ ៧ នៃឋានន្តរសក្តិក្រមការដើមខ្សែ។

ការតម្លើងទៅក្នុងឋានន្តរសក្តិមួយខ្ពស់ជាង អាចផ្តល់ឧបនិស្ស័យដល់មន្ត្រីសាមីសំរាប់កាន់មុខតំណែង ស្រប តាមឋានន្តរសក្តិថ្មីនោះ ដូចបានកំណត់ក្នុងមាត្រា ៥ នៃលក្ខន្តិកៈដោយឡែកនេះ។

**មាត្រា ១៤.-**

សន្ទស្សន៍សំរាប់ថ្នាក់ក្នុងឋានន្តរសក្តិនីមួយៗ នៃក្របខ័ណ្ឌមន្ត្រីក្រមការ និងតម្លៃឯកតានៃសន្ទស្សន៍ ព្រមទាំងរបបលាភការផ្សេងៗ ទៀតត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក។

## ជំពូកទី ៧

## បទប្បញ្ញត្តិដោយឡែក

**មាត្រា ១៥.-**

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីក្រមការ ដែលមានសញ្ញាប័ត្របរិញ្ញាប័ត្រ ឬ សញ្ញាប័ត្រសមមូល ត្រូវបានតម្លើងថ្នាក់មួយថ្នាក់ជាស្វ័យប្រវត្តិ។

**មាត្រា ១៦.-**

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីក្រមការ ត្រូវដាក់អោយចូលនិវត្តន៍នៅពេលដល់អាយុ ៥៨ ឆ្នាំ។ ចំពោះការដាក់ឱ្យចូលនិវត្តន៍ ត្រូវសំរេចដោយប្រកាសរបស់ក្រសួងមហាផ្ទៃ។

**មាត្រា ១៧.-**

សញ្ញាសក្តិ និងឯកសណ្ឋានសម្រាប់មន្ត្រីក្រមការ ត្រូវកំណត់ដោយព្រះរាជក្រឹត្យមួយដោយឡែក។

## ជំពូកទី ៨

## អន្តរប្បញ្ញត្តិ

**មាត្រា ១៨.-**

ចំនួនដំបូងនៃក្របខ័ណ្ឌមន្ត្រីក្រមការ ត្រូវកសាងចេញពីសមាហរណកម្មនៃមន្ត្រីរាជការទាំងឡាយ ដែលបច្ចុប្បន្នកំពុងបំពេញមុខតំណែង និងមុខងារពិតប្រាកដរបស់ក្របខ័ណ្ឌក្នុងរដ្ឋបាលកណ្តាល និងតាមខេត្តក្រុង។

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

**មាត្រា ១៩.-**

បទប្បញ្ញត្តិណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ២០.-**

នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា ២១.-**

ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០០

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រ សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូនសម្តេច

នាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

**សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ហត្ថលេខា**

**ស ខេង** **យូ ហុកគ្រី**

លេខ: ៧៨ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០០

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ហត្ថលេខា និង ត្រា**

**ឈាង តាន់**